# ការសម្ភាសន៍របស់អ្នកមីង អ៊ុន យឹម

កៈ អ្នកសម្ភាសន៍ គង់ ចាន់ណាក់        ខៈ អ្នកដែលត្រូវបានគេសម្ភាសន៍ អ៊ុន យឹម

## ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់អ្នកមីង អ៊ុន យឹម

សង្ខេបៈ អ្នកមីង អ៊ុន យឹម បានកើតនៅភូមិផ្ទត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ហើយសព្វថ្ងៃនេះគាត់មានអាយុប៉ែតសិបឆ្នាំហើយ គាត់មានបងប្អូនចំនួនប្រាំបួននាក់តែសព្វថ្ងៃនេះគាត់នៅសល់តែបងប្អូនចំនួនបួននាក់ប៉ុណ្ណោះ ក្រៅពីនឹងពួកគាត់បានស្លាប់អស់ហើយ។ សព្វថ្ងៃនេះគាត់រស់នៅអោយសារប្អូនប្រុសរបស់គាត់បានជួយផ្គត់ផ្គង់អោយដូចជាអង្ករអោយជារៀងរាលខែដើម្បីជួយបន្តជីវិតរបស់គាត់។ ហើយកាលសម័យសង្គ្រាមពលពតគាត់បានរស់នៅក្នុងភូមិនឹងដដែល គេបានមកជំលៀសគាត់ដែរតែគាត់មិនព្រមទៅដោយសារគាត់ខ្លាចស្លាប់ដូច្នេះគាត់បានរត់ពួនពីពួកគេនៅក្នុងព្រៃចេកក្នុងភូមិហើយបាននៅទីនោះស៊ីអត់ស៊ីឃ្លាន ហើយបានមានជីវិតដល់សព្វថ្ងៃនេះ។ ធ្វើឡើងនៅភូមិផ្ទត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ  ធ្វើឡើងនៅថ្ងៃទី២៤ ខែ០៤ ឆ្នាំ២០១៨៕

កៈ ខ្ញុំបាទឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា ដែលធ្វើឡើងដោយសាកលវិទ្យាល័យ ប៊ី វ៉ាយ យូ នៅសហរដ្ឋអាមេរិច ដោយសារសកលវិទ្យាល័យ មានគោលបំណងចង់រក្សាប្រវត្តិរបស់ប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយរបស់ពួកគាត់អាចស្គាល់ពីប្រវត្តិរបស់ជីដូនជីតានិងឪពុកម្តាយ។ ហើយការសម្ភាសន៍នេះយើងធ្វើនៅ        ថ្ងៃទី២៤ ខែ០៤ ឆ្នាំ២០១៨ ហើយការសម្ភាសន៍នេះយើងធ្វើនៅភូមិផ្ទត់ដំរីខាងត្បូង ឃុំដំរិល ស្រុក អូរាំងឪ ខេត្តត្បូងឃ្មុំ។ ហើយការសម្ភាសន៍នេះយើងនឹងថតជាសំលេង ហើយអ្នកថតរូបភាពរបស់អ្នកមីង ដើម្បីផ្ញើរទៅកាន់សាកលវិទ្យាល័យ ដើម្បីពួកគេអាចយកទៅដាក់នៅលើវេបសាយរបស់ សាកលវិទ្យាល័យ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងគិតថា អ្នកមីងយល់ព្រមអោយខ្ញុំយក    សំលេងនិងរូបថតអ្នកមីងដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យទេអ្នកមីង?

ខៈ ខ្ញុំយល់ព្រមអោយយកទៅដាក់ទៅ។

ក៖ អញ្ចឹងអរគុណច្រើនអ្នកមីង ដែលបានអោយខ្ញុំយកសំលេងហើយនឹងរូបភាពអ្នកមីងដាក់លើវេបសាយរបស់សាកលវិទ្យាល័យ។ ជាដំបូង តើអ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឈ្មោះយាយ យឹម។

ក៖ ឈ្មោះយាយ យឹម! ហើយអញ្ចឹង សំរាប់ត្រកូលរបស់អ្នកមីងមានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ អ៊ុន យឹម។

ក៖ អ៊ុន យឹម! បាទ បាទ! ហើយអញ្ចឹង តើអ្នកមីងមានឈ្មោះហៅក្រៅទេ អ្នកមីង?

ខ៖ អត់មានផង។

ក៖ អត់មានផង! ហើយអញ្ចឹង សំរាប់កាលនៅក្មេងៗ តើគេហៅអ្នកមីងថាយ៉ាងម៉េចដែរអ្នកមីង?

ខ៖ គេហៅធំយឹម។

ក៖ ធំយឹម! ហ្នឹងហើយ សំរាប់សព្វថ្ងៃនេះ តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ខ្ញុំមានអាយុប៉ែតសិបឆ្នាំគត់។

ក៖ ប៉ែតសិបឆ្នាំគត់! ហើយអញ្ចឹង តើអ្នកមីងចាំថា អ្នកមីងបានកើតនៅឆ្នាំណាទេ អ្នកមីង?

ខ៖ ខ្ញុំកើតនៅឆ្នាំរកា។

ក៖ ឆ្នាំរកាហ៎! ចុះដូចជាឆ្នាំយើងមួយពាន់ប្រាំបួនរយកៅអីចឹង តើអ្នកមីងកើតឆ្នាំណា អ្នកមីងដឹងទេ?

ខ៖ ដឹងតែថាកើតឆ្នាំរកានឹងណា។

ក៖ អញ្ចឹង អ្នកមីងមានអាយុប៉ែតសិបឆ្នាំគត់ អញ្ចឹងអ្នកមីងប្រហែលជាកើតនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយសាមសិបប្រាំបីអ្នកមីង។ អញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងបានកើតនៅខេត្តណាដែរ អ្នកមីង?

ខ៖ កើតនៅនឹង ខេត្តត្បូងឃ្មុំ។

ក៖ ហើយអញ្ចឹង តើអ្នកមីងនៅចាំឈ្មោះ ភូមិ ឃុំ ស្រុក ដែលអ្នកមីងបានកើតទេ?

ខ៖ ភូមិផ្អត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ។

ក៖ ហ្នឹងហើយ! ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ បងប្អូនខ្ញុំមានប្រាំបួននាក់ តែស្លាប់អស់ហើយនៅសល់តែបួននាក់ទេ។

ក៖ អូ! ស្លាប់អស់ខ្លះហើយនៅសល់តែបួននាក់ទេ។ ហើយអញ្ចឹង តើអ្នកមីងជួយរៀបរាប់ឈ្មោះបងប្អូនរបស់អ្នកមីងទាំងប្រាំបួននាក់នឹងបានទេ អ្នកមីង?

ខ៖ ឈ្មោះយាយយឿន យាយយៀត យាយយ៉ែម យាយញឹម យាយមី តាផូ តាភ័ណ តាអែង។

ក៖ ហើយអញ្ចឹង តើអ្នកមីងជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសារដែរអ្នកមីង?

ខ៖ ខ្ញុំជាកូនទីបួននៅក្នុងក្រុមគ្រួសារ។

ក៖ អូ! កូនទីបួន។ ហើយអញ្ចឹង សំរាប់បងប្អូនរបស់អ្នកមីង តើមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែលអ្នកមីង?

ខ៖ បងប្អូនរបស់ខ្ញុំមានស្រីប្រាំ ហើយប្រុសបីនាក់។

ក៖ ស្រីប្រាំមួយ ហើយប្រុសមានតែបីនាក់ទេ។ ហើយអញ្ចឹងសំរាប់ពេលនៅក្មេងៗ តើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់អ្នកមីង?

ខ៖ គ្មានចូលចិត្តធ្វើអ្វីទេ មើលតែក្របីមើលគោ ហើយធ្វើស្រែជាមួយគ្នា ហើយឥឡូវលែងធ្វើហើយ បើស្រែមិនតាំងមានផងឥឡូវ។

ក៖ ហើយអញ្ចឹង សំរាប់បងប្អូនរបស់អ្នកមីង តើសព្វថ្ងៃនេះពួកគាត់រស់នៅឯណាខ្លះដែរអ្នកមីង?

ខ៖ ពួកគាត់រស់នៅភូមិនឹងខ្លះ ហើយនៅភូមិច្រឡោង ហើយនឹងនៅភូមិជើងខាល។

ក៖ ហើយអញ្ចឹង សព្វថ្ងៃនេះពួកគាត់ប្រកបមុខរបរអ្វីខ្លះដែរអ្នកមីង?

ខ៖ ធ្វើតែស្រែនឹង គ្មានធ្វើអ្វីទេ។

ក៖ ធ្វើតែស្រែទេន៎អ្នកមីង!ហើយអញ្ចឹងសំរាប់អ្នកមីងតើឪពុករបស់អ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំឈ្មោះអ៊ុន។

កៈ ហើយអញ្ចឹង សព្វថ្ងៃនេះគាត់ស្លាប់ហើយ ឬគាត់នៅរស់ទេអ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ស្លាប់ប៉ុន្មានឆ្នាំហើយ។

កៈ តើឪពុករបស់អ្នកមីងគាត់បានស្លាប់អស់រយៈពេលប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ គាត់បានស្លាប់បួនដប់ឆ្នាំហើយ។

កៈ កាលដែលឪពុករបស់អ្នកមីងបានស្លាប់នឹង តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ កាលឪពុកខ្ញុំស្លាប់ ខ្ញុំអាយុចិតសិបមួយឆ្នាំ។

កៈ អូ!ពេលគាត់បានស្លាប់អ្នកមីងអាយុចិតសិបមួយឆ្នាំ។ ហើយអញ្ចឹង
តើឪពុករបស់អ្នកមីងគាត់បានស្លាប់នៅកន្លែងណាដែរអ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់បានស្លាប់នៅភូមិនឹងតែម្តង។

កៈ ហើយអញ្ចឹង តើឪពុកអ្នកមីងគាត់បានកើតនៅភូមិនឹងដែរមែនទេ អ្នកមីង?

ខៈ ឪពុកខ្ញុំគាត់កើតនៅភូមិនឹង។

កៈ អូ! កើតនៅភូមិនឹងទាំងអស់គ្នាតែម្តង។ ហើយអញ្ចឹង
តើម្តាយរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខៈ ម្តាយរបស់ខ្ញុំគាត់ឈ្មោះ យាយយស។

កៈ យាយយស! ហើយអញ្ចឹង
តើម្តាយរបស់អ្នកមីងគាត់បានកើតនៅកន្លែងណាដែរអ្នកមីង?

ខៈ ម្តាយរបស់ខ្ញុំ គាត់កើតនៅភូមិនឹងដែរ។

កៈ អូ! គាត់កើតនៅភូមិនឹងដែរ។ ហើយអញ្ចឹងសព្វថ្ងៃនេះ គាត់ស្លាប់ហើយឬអ្នកមីង?

ខៈ សព្វថ្ងៃនេះគាត់ស្លាប់បាត់ហើយ។

កៈ ហើយអញ្ចឹង ពេលដែលម្តាយរបស់អ្នកមីងបានស្លាប់
តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ពេលម្តាយរបស់ខ្ញុំបានស្លាប់ ខ្ញុំអាយុចិតសិបពីរឆ្នាំ។

កៈ អញ្ចឹងមានន័យថាពេលដែលតាស្លាប់បានមួយឆ្នាំហើយយាយស្លាប់ឆ្នាំក្រោយនឹងជាប់ជាប់គ្នា។ ហើយអញ្ចឹង សំរាប់ឪពុកម្ដាយរបស់អ្នកមីង កាលដែលពួកគាត់នៅរស់តើពួកគាត់រកស៊ីអ្វីចិញ្ចឹមជីវិតដែរអ្នកមីង?

ខៈ ឪពុកម្ដាយរបស់ខ្ញុំធ្វើស្រែនឹង គ្មានធ្វើអ្វីទៀតទេធ្វើតែស្រែនឹង។

កៈ ហើយអញ្ចឹង
ឪពុកម្ដាយរបស់អ្នកមីងអត់មានធ្វើការអីផ្សេងក្រៅពីធ្វើស្រែនឹងទេអ្នកមីង?

ខៈ អត់មានទេ មានតែធ្វើស្រែតែមួយមុខនឹងទេ។

កៈ អូ! ធ្វើតែស្រែមួយមុខនឹងទេអ្នកមីង។ ហើយអញ្ចឹងសំរាប់ឪពុករបស់អ្នកមីង
តើគាត់មានចរិត  ឬកពាដូចម្ដចដែរអ្នកមីង?

ខៈ ឪពុករបស់ខ្ញុំមានចរិតស្លូតបូត គ្មានកាចទេឪពុកខ្ញុំនោះ ស្លូតតែម្ដង
គេសរសើរគ្រប់គ្នាថា តាអ៊ុនស្លូតហើយចិត្តល្អ។

កៈ ហើយអញ្ចឹង
តើឪពុកម្ដាយរបស់អ្នកមីងធ្លាប់និយាយប្រាប់អ្នកមីងអំពីជីវិតរបស់គាត់កាលគាត់នៅក្មេងៗទេអ្នកមីង?

ខៈ គាត់មិនដែលបានប្រាប់ទេ។

កៈ មិនដែលសោះតែម្ដង! ហើយអញ្ចឹង
តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ្នកមីងទេ?

ខៈ អត់ចាំទេ មិនស្គាល់ទេ។

កៈ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់អ្នកមីងទេ?

ខៈ ជីដូនជីតាខាងម្ដាយមិនដឹងជាឈ្មោះអីទេ មិនស្គាល់ទេ។

កៈ ហើយអញ្ចឹង សំរាប់អ្នកមីង
តើអ្នកមីងបានរស់នៅខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ?

ខៈ មិនដឹងប៉ុន្មានឆ្នាំទេ បើរស់នៅនឹងតាំងពីតូចរហូតមកដល់ឥឡូវនឹងតែម្ដង។

កៈ អូ! អញ្ចឹងពេលដែលអ្នកមីងបានកើតមករស់នៅនឹងតែម្ដង។ ហើយអញ្ចឹង
តើអ្នកមីងមានបងប្អូន សាច់ញាត្តិដែលរស់នៅក្រៅប្រទេសខ្មែរយើងទេ អ្នកមីង?

ខ៖ គ្មានទេ មានតែនៅនឹងប្រទេសយើងនឹងទេ។

ក៖ ហើយអញ្ចឹង តើស្វាមីរបស់អ្នកមីង គាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ប្ដីរបស់ខ្ញុំគាត់ឈ្មោះតាគី។

ក៖ ហើយអញ្ចឹង ប្ដីរបស់អ្នកមីងត្រកូលមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ប្រាក់ គី។

ក៖ ប្រាក់ គី! ហើយអញ្ចឹង តើអ្នកមីងមាននៅចាំទេថា
អ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅពេលណាទេអ្នកមីង?

ខ៖ អត់ចាំផង ភ្លេចបាត់ហើយក្មួយអើយយូរហើយនឹង។

ក៖ អត់ចាំទេអ្នកមីង។ ហើយអញ្ចឹង ពេលដែលអ្នកមីងរៀបអាពាហ៍ពិពាហ៍ជាមួយគាត់
តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ ពេលដែលខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នឹងអាយុដប់ប្រាំឆ្នាំ។

ក៖ ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍នឹង ត្រូវបានរៀបចំឡើងដោយឪពុកម្ដាយ
ឬមួយអ្នកមីងរៀបចំឡើងដោយខ្លួនឯង?

ខ៖ ឪពុកម្ដាយគាត់ជាអ្នករៀបចំអោយយើង។

ក៖ ហើយអញ្ចឹង សំរាប់អាពាហ៍ពិពាហ៍ដែលរៀបចំឡើងដោយឪពុកម្ដាយរបស់អ្នកមីង
តើមានដូចជាថ្លៃជំនូនដែរឬទេអ្នកមីង?

ខ៖ ជំនូនកាលនឹងដប់ម៉ឺន។

ក៖ ដប់ម៉ឺនលុយខ្មែរយើងនឹងឬអ្នកមីង?

ខ៖ ហ្នឹងហើយ ដប់ម៉ឺនលុយខ្មែរយើងនឹង ច្រើនហើយដប់ម៉ឺននឹងកាលជំនាន់នឹង។

ក៖ ហើយអញ្ចឹង សំរាប់ជំនាន់នឹងមានមួយជីតម្លៃប៉ុន្មានដែរអ្នកមីង?

ខ៖ មិនដឹងដែរ ដូចជាអត់ចាំទេកាលនឹង។

ក៖ អត់ដឹងដែរអ្នកមីង!
ហើយអញ្ចឹងសំរាប់ចងអាពាហ៍ពិពាហ៍របស់អ្នកមានកូនចំនួនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ មានកូនពីរនាក់។

ក៖ ហើយអញ្ចឹង កូនរបស់អ្នកទាំងពីរនាក់នឹងមានឈ្មោះអ្វីខ្លះដែរអ្នកមីង?

ខ៖ បងគេឈ្មោះផិត ហើយនឹងកូនពៅឈ្មោះចាប។

ក៖ មានតែពីរនាក់នឹងទេ។ ហើយអញ្ចឹង សព្វថ្ងៃនេះកូនរបស់អ្នកមីង ពួកគាត់រកស៊ីអ្វីដែរអ្នកមីង?

ខ៖ សព្វថ្ងៃនឹងពួកគាត់ដើរស៊ីឈ្នួលគេរហូតទៅ បើយើងគ្មានស្រែធ្វើនឹងគេផង។

ក៖ ហ្នឹងហើយ យើងដើរស៊ីឈ្នួលគេយកលុយប្រាក់ខែទៅ។ ហើយអញ្ចឹងសំរាប់អ្នកមីង ចេះអាន និងសរសេរអក្សរខ្មែរទេអ្នកមីង?

ខ៖ មិនចេះទេ អត់ចេះសោះតែម្ដង។

ក៖ មិនចេះសោះតែម្ដងអ្នកមីង! ហើយអញ្ចឹង អ្នកមីងចេះនិយាយភាសាផ្សេងៗក្រៅពីភាសាខ្មែរទេ?

ខ៖ អត់ចេះផង។

ក៖ ហើយអញ្ចឹង តើអ្នកមីងអត់ដែលបានរៀនសោះតែម្ដង ឬមួយបានរៀនខ្លះដែរ អ្នកមីង?

ខ៖ បានរៀនដែរ តែវាមិនចាំទេព្រោះយូរហើយ ហើយបានរៀនតិចតួចនឹង។

ក៖ អូ! អញ្ចឹងអ្នកមីងធ្លាប់បានរៀនដែរ! ហើយអញ្ចឹងកាលដែលអ្នកមីងបានរៀននោះ តើអ្នកមីងរៀនបានដល់ថ្នាក់ទីប៉ុន្មានដែរ អ្នកមីង?

ខ៖ មិនចាំទេក្មួយអើយ ភ្លេចហើយ។

ក៖ ហើយអញ្ចឹង កាលដែលអ្នកមីងបានរៀននឹង តើអ្នកមីងរៀននៅសាលាណាដែរ អ្នកមីង?

ខ៖ ខ្ញុំរៀននៅវត្តដំរិលយើងនឹង។

ក៖ ហើយអញ្ចឹង កាលនោះរៀននៅក្នុងកុដរបស់លោក ឬមួយយើងរៀននៅក្នុងសាលាអ្នកមីង?

ខ៖ កាលនោះរៀនជាមួយលោក ដល់លោកវាយទៅរត់មកផ្ទះវិញ។

ក៖ ហើយអញ្ចឹង
អ្នកមីងធ្លាប់មានមិត្តជិតស្និតដែលធំធាត់មកជាមួយគ្នាតាំងពីក្មេងរហូតមកដល់ឥឡូវទេអ្នកមីង?

ខ៖ អត់ដែលមានទេក្មួយអើយ។

ក៖ អត់មានតែម្តងអ្នកមីង! ហើយអញ្ចឹង តើអ្នកមីងមានស្រែចំការទេអ្នកមីង?

ខ៖ គ្មានទេ គ្មានតែម្តង។

ក៖ គ្មានទេអ្នកមីង។

ខ៖ គ្មានស្រែ គ្មានចំការទ មានតែដីភូមិនឹងតិចនឹងសំរាប់រស់នៅរាល់ថ្ងៃនឹង។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានធ្វើអ្វើដើម្បីចិញ្ចឹមជីវិតទេអ្នកមីង រាល់ថ្ងៃនឹង?

ខ៖ អត់មានទេ គេចែកអង្ករអោយហូបទេរាល់ថ្ងៃនឹង។

ក៖ ហើយអញ្ចឹង តើនរណាគេជាអ្នកចែកអង្ករអោយអ្នកមីងហូបដែរ អ្នកមីង?

ខ៖ ប្អូនរបស់ខ្ញុំដែលនៅភូមិច្រឡោង។

ក៖ អូ! ប្អូនរបស់អ្នកមីងជាអោយចែកអោយ! ហើយអញ្ចឹងសំរាប់អ្នកមីង
តើមានម្ហូបណាដែរអ្នកមីងចូលចិត្តហូបជាងគេទេ អ្នកមីង?

ខ៖ មិនដឹងជាហូបអីទេ បើយើងអត់នឹង ហូបតែប្រហុក ហូបតែអំបិលនឹង។

ក៖ អូ! ហ្នឹងហើយ!

ខ៖ បើយើងមិនបានទៅរកអីនឹងគេផង បានអីមកហូប។

ក៖ ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរ
តើអ្នកមីងមានល្បែងប្រជាប្រិយណាដែលអ្នកមីងចូលចិត្តលេងតាំងពីក្មេងរហូតមកដល់ឥលូវ?

ខ៖ គ្មានទេ។

ក៖ ហើយអញ្ចឹងសំរាប់បទចម្រៀងវិញ
តើមានបទចម្រៀងមួយណាដែលអ្នកមីងចូលចិត្តស្តាប់ ហើយរៀនច្រៀងតាមទេ?

ខ៖ គ្មានទេ សូម្បីតែរាល់ថ្ងៃនឹងគេលេងល្ខោនបាក់មេឃក៏ដោយ
ក៏នៅតែដេកនៅនឹងផ្ទះដែរ។

ក៖ មិនចេញទៅណាទេអ្នកមីង។

ខ៖ អត់ទៅទេ មិនទៅតែម្តង អោយគេទៅស្ងាត់ទៅ មីងនៅតែនឹងផ្ទះទេ។

ក៖ ហើយអញ្ចឹង
នៅក្នុងក្រុមគ្រួសាររបស់អ្នកមីងមាននរណាដែលចេះលេងឧបករណ៍ភ្លេងទេអ្នកមីង?

ខ៖ ក្នុងក្រុមគ្រួសារខ្ញុំគ្មាននរណាចេះលេងទេ។

ក៖ ហើយអញ្ចឹង សំរាប់ផ្ទះរបស់អ្នកមីងកាលដែលអ្នកមីងនៅតូច
តើផ្ទះរបស់អ្នកមីងមានលក្ខណៈយ៉ាងម៉េចដែរអ្នកមីង?

ខ៖ មិនដឹងដែរ ភ្លេចអស់ហើយ។

ក៖ កាលដែលអ្នកមីងនៅតូចៗ ផ្ទះខ្ពស់ផ្ទះទាប ឬមួយផ្ទះយ៉ាងម៉េចដែរ?

ខ៖ ផ្ទះខ្ពស់។

ក៖ ហើយអញ្ចឹងផ្ទះនឹងធ្វើឡើងដោយសំភារៈអ្វីខ្លះដែរអ្នកមីង?

ខ៖ ធ្វើឡើងដោយដើមត្នោត ហើយនឹងឫស្សី។ រនូតដើមត្នោត ហើយខាងលើសុទ្ធតែឫស្សី
ហើយប្រក់តែស្បូវហើយនឹងចំបើងទេ ទើបតែឥឡូវនឹងកូនទៅដាំជំឡូងនឹងទេ
បានផ្ទះនៅនឹងនោះ។

ក៖ ហើយអញ្ចឹង ផ្ទះដែលអ្នកមីងនៅតូចៗនឹង
ផ្ទះនឹងធ្វើឡើងដោយខ្លួនឯងឬមួយអ្នកមីងជួលគេអោយធ្វើអោយ?

ខ៖ ធ្វើដោយខ្លួនឯងនឹងឫស្សីស្រណុកសឹងងាប់ ពុះជ្រាក់
ហើយឡើងប្រក់ដោយខ្លួនឯងទៀត។

ក៖ ហើយអញ្ចឹង តើនរណាគេដែលជាអ្នកបង្រៀនអ្នកមីងអោយធ្វើផ្ទះមួយនឹង
ឬមួយអ្នកមីងចេះធ្វើវាដោយខ្លួនឯងតែម្តង?

ខ៖ បើវាទល់ មិនធ្វើដោយខ្លួនឯង បើមិនចឹងម៉េចបានផ្ទះនៅ។

ក៖ ហើយអញ្ចឹង មានអ្នកជិតខាងជួយប្រាប់ ឬមួយអ្នកមីងចេះតែធ្វើៗទៅ?

ខ៖ ចេះតែធ្វើខ្លួនឯងអោយតែបាននៅទៅ កាលនោះប្រក់ចំបើងនឹង
ទើបតែកូនទៅធ្វើជំឡុងទេ ទើបបានធ្វើផ្ទះល្អនៅនឹងគេទៅ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានជំនាញដែលបន្តវេនពីក្រុមគ្រួសារទេអ្នកមីង
ដូចជាវេញវល្លិ៍ផ្តៅ ឬមួយក្លូរស្កុរត្នោតអីចឹង?

ខ៖ អត់មានទេ។

ក៖ អត់មានទេ! ហើយអញ្ចឹងអ្នកមីងអាចជួយប្រាប់ខ្ញុំបានទេ
ពេលវេលាណាដែលអ្នកមីងលំបាកជាងគេនៅក្នុងជីវិតរបស់អ្នកមីង?

ខ៖ មួយពោះម្តាយមកខ្ញុំពិបាកជាងគេ ពិបាកមែនទែន
ពិបាករហូតមកដល់ឥឡូវនឹងតែម្តង។ បានអាប្អូនវាជួយបើកអង្ករអោយហូបយាយនឹង
មួយភូមិមួយស្រុកផ្ទត់ដំរីនឹងខ្ញុំពិបាកជាងគេ។

ក៖ ហើយអញ្ចឹង កាលជំនាន់ពលពតតើអ្នកមីងបានរស់នៅកន្លែងណាដែរអ្នកមីង?

ខ៖ ជំនាន់ពលពតខ្ញុំរស់នៅភូមិនឹងតែម្តង។

ក៖ ហើយអញ្ចឹង ពួកពលពតអត់មានបានជំលៀសអ្នកមីងទៅកន្លែងណាផ្សេងទេអ្នកមីង?

ខ៖ អត់មានបានទៅផង មានគេទៅកន្លែងផ្សេង តែមីងអត់ទៅនឹងគេផង
បើពិបាកជាងគេទៅណា ខ្លាចស្លាប់អត់ហ៊ានទៅណាទេ។

ក៖ ហើយអញ្ចឹង ពេលដែលមានពួកពលពតចូលអញ្ចឹងអី នៅក្នុងស្រុកភូមិយើងនឹង
ដូចជាអត់មានបញ្ហាអី ឬមួយគេធ្វើបាបយើងដែរ អ្នកមីង?

ខ៖ មិនបានធ្វើបាបទេ បើយើងពិបាកចឹង យើងចេះតែរត់គេចតែនៅក្នុងភូមិនឹងទៅ។

ក៖ អូ! អញ្ចឹងអ្នកមីងគ្រាន់តែរត់គេចនៅក្នុងភូមិនឹងទេអ្នកមីង។

ខ៖ មិនទៅណាឆ្ងាយពីផ្ទះសោះ រត់គេចតែនឹងព្រៃចេកនឹងទៅ។

ក៖ អូ! អញ្ចឹងគេរកយើងអត់ឃើញដែរអ្នកមីង?

ខ៖ គេរកយើងអត់ឃើញ បើយើងពួននៅនឹងព្រៃចេក ពួកវាបរមករកយើងដែរ
តែវារកយើងអត់ ឃើញ។

ក៖ ទល់តែរកអត់ឃើញចឹងទៅពួកវាក៏ចេញទៅផុតទៅ
ហើយយើងចេះតែនៅនឹងភូមិនឹងរហូតទៅ។

ខ៖ ហ្នឹងហើយ យើងចេះតែនៅនឹងភូមិនឹងរហូតទៅ នៅនឹងព្រៃចេកនឹងទៅ
ស៊ីអត់ស៊ីឃ្លាននៅនឹងទៅ។

ក៖ ហើយអញ្ចឹង អ្នកមីងធ្លាប់មានបទពិសោធន៍ដែលសប្បាយៗទេ ដូចជារៀបការកូន
រៀបការចៅ រៀបការក្មួយ ឬមួយបុណ្យទាននៅក្នុងផ្ទះ ធ្លាប់មានទេអ្នកមីង?

ខ៖ ធ្លាប់មានដែរ តែខ្ញុំមិនដែលបានទៅ
មិនដឹងជាសប្បាយយ៉ាងម៉េចបើយើងមិនដែលទៅផង។

ក៖ ហើយអញ្ចឹង កាលអ្នកមីងនៅក្មេង អ្នកមីងធ្លាប់មានក្ដីសង្ឃឹមថា
ធំឡើងអ្នកមីងចង់អ្វីដែរអ្នកមីង?

ខ៖ ធ្លាប់មាន តែទៅមិនរួច មិនអីទៅបើយើងគ្មានអង្ករគ្មានស្រូវ។

ក៖ ហើយអញ្ចឹង បើសិនអ្នកមីងចង់ផ្ដាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយ
តើអ្នកមីងចង់ផ្ដាំផ្ញើរអ្វីខ្លះទៅកាន់ពួកគាត់ អ្នកមីង?

ខ៖ អោយកូនចៅប្រឹងប្រែងរកស៊ីកុំអោយក្រលំបាក។

ក៖ ហើយអញ្ចឹង បើសិនអ្នកមីងចង់អោយពួកគាត់ជៀសវាង
តើអ្នកមីងចង់អោយពួកគាតជៀសវាងពីអ្វីខ្លះដែរអ្នកមីង?

ខ៖ អោយជៀសផុតពីរឿងមិនល្អមកដល់ពួកគេ
ពួកដែលមានចិត្តអាក្រក់ៗនឹងកុំអោយមកជិតកូនចៅ
ហើយគ្រឿងញៀនអីកុំអោយមកក្បែរ។

ក៖ ហ្នឹងហើយ ព្រោះអីយើងចង់អោយពួកគាត់មានសេចក្ដីសុខ។
ហើយអញ្ចឹងសំរាប់ខ្ញុំចុងក្រោយនេះ ខ្ញុំសូមជូនពរមីង
ហើយអរគុណមីងច្រើនសំរាប់ពេលវេលាដែលអ្នកមីងបានអោយខ្ញុំសម្ភាសន៍ពីខ្សែជីវិតរបស់អ្នកមីង ហើយខ្ញុំសូមជូនពរអ្នកមីង អោយមានសុខភាពល្អ មានកំលាំងមាំមួន
មានប្រាជ្ញាល្អណាមីងណា  ហើយសូមជូនពរដល់កូនចៅរបស់អ្នកមីងមានសុខភាពល្អ
មានប្រាជ្ញាវាងវៃ មានកំលាំងមាំមួន
ដើម្បីប្រកបមុខរបររកស៊ីអីអោយចេះតែរីកចំរើនទៅមុខរហូត ហើយខ្ញុំសង្ឃឹមថា
តាមរយៈការសម្ភាសន៍មួយនេះនឹងជួយដល់កូនចៅអ្នកមីងរៀនហើយនឹងចងចាំជីវិតរបស់អ្នកមីង ថាជីវិតរបស់លោកយាយរបស់ខ្ញុំគាត់លំបាកណាស់
ដើម្បីជួយអោយកូនចៅអ្នកមីងផុតពីការលំបាកនឹងទៅ។ អរគុណច្រើនអ្នកមីង។